ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

## រាជរដ្ឋាភិបាលកម្ពុជា

# គោលនយោបាយជាតិ ស្តីពី វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍ ឆ្នាំ២០២០ - ២០៣០

ប្រវត្តិសាស្ត្រ និងវប្បធម៌



សេដ្ឋកិច្ច



សង្គម



បរិស្ថាន





បដិវត្តន៍ឧស្សាហកម្មទី១-យន្តកម្ម



បដិវត្តន៍ឧស្សាហកម្មទី២-អគ្គិសនី



បដិវត្តន៍ឧស្សាហកម្មទី៣-ព័ត៌មានវិទ្យា




បដិវត្តន៍ឧស្សាហកម្មទី៤-បណ្តាញបញ្ញាសិប្បនិម្មិត

*« ពង្រឹងមូលដ្ឋានគ្រឹះ និងកែលម្អបរិយាកាសនៃវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដើម្បីអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ប្រកបដោយចីរភាព និងគុណភាពជីវិតប្រជាជនឲ្យកាន់តែប្រសើរ សំដៅសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ »*

ក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## រាជរដ្ឋាភិបាលកម្ពុជា

# គោលនយោបាយជាតិ
# ស្តីពី
# វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
# ឆ្នាំ២០២០-២០៣០

ក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

## អារម្ភកថា

រាជរដ្ឋាភិបាលមានទិសដៅអភិវឌ្ឍប្រទេសឱ្យកាន់តែប្រសើរប្រកបដោយបរិយាបន្ននិងចីរភាព ផ្តល់ឱ្យប្រជាជននូវសេចក្តីសុខ រក្សាបាននូវឯករាជ្យភាព បូរណភាពដែនដី និងប្រទេសជាតិមានសន្តិសុខនិងសុវត្ថិភាពសង្គមល្អ។ សម្រាប់ទិសដៅនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០សំដៅធ្វើឱ្យកម្ពុជាបានក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០និងជាប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ២០៥០។

ដើម្បីឆ្លើយតបទៅនឹងការកើនឡើងនៃតម្រូវការរបស់ប្រទេសជាតិនេះនិងនៅក្នុងបរិការណ៍ដែលធនធានធម្មជាតិមានកម្រិតនិងការប្រកួតប្រជែងក្នុងតំបន់និងសកលលោកកាន់តែស្រួចស្រាវ យើងត្រូវរួមគ្នាខិតខំអភិវឌ្ឍវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ឱ្យបានជាកម្លាំងជំរុញ និងជាកាតាលីករសម្រាប់ជួយឱ្យសម្រេចបាននូវតម្រូវការអភិវឌ្ឍន៍។

ការដាក់ចេញនូវគោលនយោបាយជាតិស្តីពីវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍នេះ គឺជាឆន្ទៈនិងជាការតម្រង់ទិសរបស់រាជរដ្ឋាភិបាលដើម្បីជម្នះកត្តាប្រឈមនានា សំដៅជំរុញការស្រាវជ្រាវវិទ្យាសាស្ត្រនិងនវានុវត្តន៍ឱ្យបានជាផលិតផលដែលកាន់តែប្រសើរ វិធីសាស្ត្រដែលលើកកម្ពស់ផលិតភាព និងសេវាកម្មដែលមានការពេញចិត្តពីប្រជាជនទូទៅ។

រាជរដ្ឋាភិបាលឈានមុខលើកិច្ចការនេះ ដោយបានផ្តល់អាទិភាពទីមួយដល់ការអភិវឌ្ឍធនធានមនុស្ស ពង្រឹងមូលដ្ឋានវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា និងប្រព័ន្ធអេកូនវានុវត្តន៍ជាតិ សំដៅជំរុញសមត្ថភាពធនធានមនុស្សដែលចូលរួមក្នុងខ្សែចង្វាក់អភិវឌ្ឍពុទ្ធិនេះឱ្យមានលទ្ធភាពលើកស្ទួយឧស្សាហកម្មនិងសេវាកម្មជាតិប្រកបដោយកម្លាំងប្រកួតប្រជែង។

ដើម្បីសម្រេចកិច្ចការទាំងអស់នេះបាន ខ្ញុំសូមឱ្យគ្រប់ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល វិស័យឯកជន សង្គមស៊ីវិល និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ចូលរួមអនុវត្តគោលនយោបាយជាតិនេះជាប្រព័ន្ធ និងសង្ឃឹមយ៉ាងមុតមាំថា ដៃគូអភិវឌ្ឍគាំទ្រដល់កិច្ចការដ៏មានសារៈសំខាន់នេះ ធ្វើឱ្យកម្ពុជាសម្រេចបាននូវការអនុវត្តរបៀបវារៈអភិវឌ្ឍជាតិរបស់ខ្លួនផងនិងចូលរួមចំណែកសម្រេចបាននូវការអនុវត្តរបៀបវារៈអភិវឌ្ឍសកលផង។

ថ្ងៃ ... ខែ ... ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ២០១៩

**ហ៊ុន សែន**

# មាតិកា

**១- សេចក្ដីផ្ដើម** ..... ១
**២- ចក្ខុវិស័យ** ..... ៣
**៣- គោលបំណង** ..... ៣
**៤- គោលដៅ** ..... ៣
**៥- យុទ្ធសាស្ត្រ** ..... ៣
៥.១- កសាងនិងពង្រឹងធនធានមនុស្សឱ្យបានគ្រប់គ្រាន់ ទាំងបរិមាណ ទាំងគុណភាព និងសមាសភាព មានសីលធម៌វិជ្ជាជីវៈ ដោយពិនិត្យពិចារណាទៅលើកត្តាសមភាពយេនឌ័រ ..... ៤
៥.២- ផ្ដល់លទ្ធភាពឱ្យធនធានមនុស្សឆ្នើមផ្នែក វ.ប.ន. បំពេញភារកិច្ចឈានមុខ និងមានយន្តការសម្រាំង និងលើកទឹកចិត្តសមស្រប ដើម្បីឱ្យបានធនធានមនុស្សផ្នែក វ.ប.ន.ជាតិ ពេញសមត្ថភាព ..... ៤
៥.៣- ផ្ដល់លទ្ធភាពដល់សកម្មភាពស្រាវជ្រាវនិងអភិវឌ្ឍជាតិប្រកបដោយប្រសិទ្ធភាពនិងសក្តិសិទ្ធិភាព ដោយផ្ដោតលើការសម្របបច្ចេកវិទ្យាដែលទទួលបានទៅនឹងស្ថានភាពជាក់ស្ដែងក្នុងស្រុកជាមួយគ្នានោះ បង្កើនសមត្ថភាពស្រូបយកបច្ចេកវិទ្យាអន្តរជាតិ ..... ៤
៥.៤- កសាងនិងពង្រឹងប្រព័ន្ធអេកូនវានុវត្តន៍ឱ្យបានប្រកបដោយជវភាព មានសមត្ថភាពសំយោគ បច្ចេកវិទ្យា និងវិស្វកម្មឱ្យបានជាស្នាដៃជាតិ មានកម្រិតនវានុវត្តន៍កាន់តែប្រសើរ សំដៅលើកស្ទួយ ឧស្សាហកម្ម និងធុរកិច្ចជាអាទិភាពជាតិ បម្រើឱ្យការប្រើប្រាស់ក្នុងស្រុកនិងការនាំចេញ ដើម្បីការអភិវឌ្ឍកាន់តែប្រសើរឡើង ..... ៥
៥.៥- បណ្ដុះឱ្យមានវប្បធម៌ វ.ប.ន. នៅក្នុងសង្គម ប្រកបដោយបរិយាបន្ន មានទំនុកចិត្តនិងជំនឿជាសាធារណៈ លើផលិតផលនិងសេវាបច្ចេកវិទ្យាជាតិ ទទួលបាននូវការពេញចិត្តទៅលើលទ្ធផលនៃការខិតខំនិងការវិនិយោគលើការអភិវឌ្ឍ វ.ប.ន.របស់ខ្លួន ក៏ដូចជាទៅលើការកែទម្រង់អភិបាលកិច្ចផ្នែក វ.ប.ន. ..... ៦
**៦- ផែនការសកម្មភាព** ..... ៧
៦.១- ការបង្កើតយន្តការ ..... ៧
៦.២- ការបង្កើតក្របខ័ណ្ឌគតិយុត្ត ..... ៧
៦.៣- ការគាំទ្រហិរញ្ញវត្ថុ ..... ៨
៦.៤- ការអភិវឌ្ឍធនធានមនុស្ស ..... ៨
៦.៥- ដំណើរការអនុវត្ត ..... ៨
**៧- ការតាមដានត្រួតពិនិត្យនិងការវាយតម្លៃ** ..... ៨
**៨- សេចក្ដីសន្និដ្ឋាន** ..... ៩
**សន្ទានុក្រម** ..... ១០
**បញ្ជីពាក្យកាត់** ..... ១៤

## ១- សេចក្តីផ្តើម

វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ដែលហៅកាត់ថា វ.ប.ន. (Science, Technology, and Innovation ឬ STI) ត្រូវបានទទួលស្គាល់ជាសកលថាជាកម្លាំងចលករសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព ធ្វើឱ្យកាន់តែប្រសើរឡើងនូវជីវភាពសង្គម និងផ្តល់ដំណោះស្រាយលើបញ្ហាបរិស្ថាន ដែលជាកត្តាមូលដ្ឋានគ្រឹះទាំងបីសម្រាប់ការរស់រានសុខសាន្តចីរកាលរបស់មនុស្សជាតិ។ ក្នុងក្របខ័ណ្ឌជាតិ ការវិនិយោគលើវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដែលមានយុទ្ធសាស្ត្រនិងគោលនយោបាយត្រឹមត្រូវក៏នឹងជួយឱ្យសម្រេចបាននូវយុទ្ធសាស្ត្រអភិវឌ្ឍន៍នានារបស់រាជរដ្ឋាភិបាល ឈានដល់ការសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ សំដៅធ្វើឱ្យកម្ពុជា បានក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០និងជាប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ២០៥០ និងក្នុងក្របខ័ណ្ឌអន្តរជាតិ គឺការសម្រេចបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។

សារៈសំខាន់និងភាពចាំបាច់នៃ វ.ប.ន. គឺអាស្រ័យដោយវាជាផ្នែកពុទ្ធិនិងមិនអាចខ្វះបាននៃគ្រប់ផលិតផល វិធីសាស្ត្រ និងសេវាកម្ម ដែលជាស្នាដៃរបស់មនុស្សជាតិ។ ភាពមិនអាចខ្វះបាននេះ គឺតម្រូវឱ្យយើងមានលទ្ធភាពបង្កើតនិងមានលទ្ធភាពធ្វើឱ្យកាន់តែប្រសើរឡើងនូវផ្នែកនេះដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព។ ផ្នែកពុទ្ធិ(គ្មានរូប) គឺតម្រូវឱ្យយើងមានឆន្ទៈខ្ពស់ក្នុងការវិនិយោគនិងការប្តេជ្ញាចិត្តរួមគ្នាអនុវត្ត ដើម្បីទទួលបានលទ្ធផលស្របនឹងការរំពឹងទុក។

ទោះបីជា វ.ប.ន. អាចត្រូវបានទទួលដោយមធ្យោបាយនិងប្រភពផ្សេងៗក្តី ក៏ការស្រាវជ្រាវនិងអភិវឌ្ឍន៍នៅតែជាកិច្ចការគន្លឹះមិនអាចខ្វះបាននៅក្នុងការបង្កើត និងការកសាងសមត្ថភាពចាប់យកបច្ចេកវិទ្យា ដោយតម្រូវការធ្វើមូលដ្ឋាននីយកម្ម បច្ចេកវិទ្យា ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការក្នុងស្រុក ក៏ដូចជាដើម្បីការកសាងសមត្ថភាពប្រកួតប្រជែងជាសកលរបស់ផលិតផលនិងស្នាដៃជាតិ។

កិច្ចការជំរុញនិងលើកកម្ពស់ការស្រាវជ្រាវនិងអភិវឌ្ឍន៍ទាំង៣កម្រិតដែលរួមមាន ១- ការស្រាវជ្រាវបឋម ២- ការស្រាវជ្រាវអនុវត្តន៍ និង ៣- ការអភិវឌ្ឍដោយពិសោធន៍ ទាមទារឱ្យមានយុទ្ធសាស្ត្រនិងយុទ្ធវិធីសមស្របនឹងលទ្ធភាពជាតិជាក់ស្តែង។ ស្ថាប័នប្រតិបត្តិករចម្បងទាំងបីនៃការស្រាវជ្រាវនិងអភិវឌ្ឍន៍រួមមាន ១- សាកលវិទ្យាល័យដែលសមស្របសម្រាប់ការស្រាវជ្រាវបឋមជាចម្បង ២- វិទ្យាស្ថានស្រាវជ្រាវដែលត្រូវបានរំពឹងសម្រាប់ការបង្កើតបច្ចេកវិទ្យាថ្មី និង ៣- សហគ្រាសអាជីវកម្មដែលមានគោលបំណងចម្បងគឺការអភិវឌ្ឍដោយពិសោធន៍។ អន្តរកម្មរវាងស្ថាប័នទាំងបី គឺជាការចាំបាច់ ដើម្បីឱ្យចំណេះដឹងដែលទទួលបានពីការសិក្សានិងស្រាវជ្រាវអាចត្រូវបានជំរុញចេញជាផលិតផលនិងស្នាដៃជាតិ ឆ្លើយតបទៅនឹងតម្រូវការទីផ្សារក្នុងរយៈពេលចាំបាច់។ លើសពីនេះ ការនាំយកស្នាដៃនៃលទ្ធផលស្រាវជ្រាវថ្មីៗទៅទីផ្សារតែងជួបនូវកត្តាប្រឈម និងទាមទារឱ្យមានការគាំទ្រឬអន្តរាគមន៍ តាមរយៈពាណិជ្ជូបនីយកម្មនិងកម្មវិធីបណ្តុះធុរកិច្ច ជាអាទិ៍ ដើម្បីធ្វើឱ្យលទ្ធផលទាំងនេះអាចទទួលបានជោគជ័យក្នុងកម្រិតសមស្រប។

ក្នុងបរិការណ៍ដែលធនធាន សមត្ថភាព និងពេលវេលាសម្រាប់ការអភិវឌ្ឍនៅមានកម្រិត អាទិភាពត្រូវផ្តល់លើការអភិវឌ្ឍដោយពិសោធន៍ តាមរយៈការនាំចូលបច្ចេកវិទ្យា និងការធ្វើមូលដ្ឋាននីយកម្មបច្ចេកវិទ្យាទាំងនោះ។ ជាមួយគ្នានេះ សមត្ថភាពជាតិក្នុងការស្រូបយកបច្ចេកវិទ្យាត្រូវបានពង្រឹងជាលំដាប់។ ការសម្រេចបាននូវភារកិច្ចជាយុទ្ធសាស្ត្រនេះក្នុងរយៈពេលខ្លីនឹងនាំមកនូវផលប្រយោជន៍សេដ្ឋកិច្ចសម្រាប់ជួយផ្តល់ធនធាន ដល់វដ្តនៃការវិនិយោគបន្ទាប់។ ជាជំហានៗ ការវិនិយោគលើការស្រាវជ្រាវបឋម និងការស្រាវជ្រាវអនុវត្តន៍ គួរត្រូវបានបង្កើនឡើងដើម្បីទទួលបានកម្រិតនវានុវត្តន៍កាន់តែខ្ពស់ សំដៅបង្កើនកម្រិតប្រកួតប្រជែងកាន់តែខ្លាំង និងតម្លៃបន្ថែមកាន់តែច្រើនជាលំដាប់។

បញ្ហាប្រឈមចម្បងរបស់រាជរដ្ឋាភិបាល នៅក្នុងដំណាក់កាលបឋមនៃការជំរុញការអភិវឌ្ឍ វ.ប.ន. គឺភាពមានកម្រិតនៃធនធានជាតិ។ ទោះជាយ៉ាងនេះក្តី រាជរដ្ឋាភិបាលចាំបាច់ត្រូវឈានមុខលើការវិនិយោគផ្នែកការស្រាវជ្រាវនិងអភិវឌ្ឍន៍សម្រាប់រយៈពេលមធ្យម ក្នុងពេលដែលរាជរដ្ឋាភិបាលមានតម្រូវការជាអាទិភាពជាតិផ្សេងទៀត។ តម្រូវការនេះគឺអាស្រ័យដោយវិស័យឯកជនមិនទាន់មានសមត្ថភាព ទំនុកចិត្ត និងបទពិសោធក្នុងកិច្ចការស្រាវជ្រាវនិងអភិវឌ្ឍន៍។ ភាពចាំបាច់នេះ ជាមួយគ្នានឹងភាពចាំបាច់នៃកិច្ចសហការជាតិ និងអន្តរជាតិ ទាមទារឆន្ទៈដ៏ខ្ពង់ខ្ពស់របស់ប្រមុខនៃរាជរដ្ឋាភិបាលដើម្បីជោគជ័យសម្រាប់ការអភិវឌ្ឍជារួម។

ក្នុងន័យនេះ កម្ពុជាត្រូវធ្វើអន្តរាគមន៍តាមរយៈការបង្កើតគោលនយោបាយ និងការប្តេជ្ញាចិត្តអនុវត្តដើម្បីពង្រឹង និងកាត់បន្ថយគម្លាតផ្នែក វ.ប.ន. ពីបណ្តាប្រទេសក្នុងតំបន់ នៅក្នុងបរិការណ៍នៃពេលវេលា និងទីតាំងភូមិសាស្ត្រ។ ការវិនិយោគលើផ្នែកនេះមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍសង្គម សេដ្ឋកិច្ចឱ្យបានទាន់ពេលវេលា សំដៅសម្រេចឱ្យបាននូវចក្ខុវិស័យឆ្នាំ២០៥០ និងចំពោះមុខគឺការសម្រេចឱ្យបាននូវយុទ្ធសាស្ត្រ និងផែនការជាតិ។

ការអភិវឌ្ឍ វ.ប.ន. មានលក្ខណៈអន្តរវិស័យ និងកម្រិតជំនាញខ្ពស់ តម្រូវឱ្យមានការអនុវត្តរួមគ្នាពីបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ ដោយមានការពិចារណាលើតួនាទីភារកិច្ច និងគោលនយោបាយដែលមានស្រាប់។ វ.ប.ន. មានវិសាលភាពធំធេង ដូចនេះរាជរដ្ឋាភិបាលកំណត់កិច្ចការអាទិភាព ពង្រឹងនិងជំរុញការប្រើប្រាស់ធនធានមនុស្សដែលបានកសាងតាមរយៈប្រព័ន្ធអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈដើម្បីបង្កើតស្នាដៃ វ.ប.ន. ឬលទ្ធភាពពុទ្ធិ ក្នុងគោលដៅសម្រេចបាននូវទិសដៅពិពិធកម្មផលិតកម្មជាតិដែលមានលក្ខណៈប្រកួតប្រជែង វិធីសាស្ត្រប្រកបដោយប្រសិទ្ធភាព និងសេវាកម្មដែលមានភាពទាក់ទាញ ដើម្បីការអភិវឌ្ឍសង្គម សេដ្ឋកិច្ចប្រកបដោយចីរភាព។

ការរៀបចំគោលនយោបាយជាតិ វ.ប.ន. គឺជាការកំណត់យុទ្ធសាស្ត្រនិងយុទ្ធវិធីដើម្បីសម្រេចបាននូវគោលដៅដែលបានកំណត់ សមស្របតាមបរិការណ៍ជាក់ស្តែងនៃប្រទេសជាតិ សំដៅជំរុញនិងលើកកម្ពស់ចំណេះដឹងដែលទទួលបានពីការអប់រំឱ្យឈានទៅដល់កម្រិតសេដ្ឋកិច្ចពុទ្ធិ ដើម្បីផ្តល់លទ្ធភាពដល់ការសម្រេចបាននូវរបៀបវារៈអភិវឌ្ឍន៍ជាតិ ដូចជាចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ ប្រកបដោយចីរភាព។

## ២- ចក្ខុវិស័យ

ប្រទេសកម្ពុជាមានសក្តានុភាពផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ជាកម្លាំងជំរុញល្បឿននៃការអភិវឌ្ឍសង្គម សេដ្ឋកិច្ចប្រកបដោយបរិយាបន្ននិងចីរភាព ធ្វើឱ្យសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។

## ៣- គោលបំណង

គោលនយោបាយជាតិនេះមានគោលបំណងពង្រឹងមូលដ្ឋានគ្រឹះនិងកែលម្អបរិយាកាសនៃវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដើម្បីអភិវឌ្ឍប្រកបដោយចីរភាពនិងលើកកម្ពស់គុណភាពជីវិតប្រជាជនឱ្យកាន់តែប្រសើរ និងអភិវឌ្ឍប្រព័ន្ធអេកូនវានុវត្តន៍នៅគ្រប់កម្រិតនិងគ្រប់វិស័យ។

## ៤- គោលដៅ

ដើម្បីសម្រេចចក្ខុវិស័យនិងគោលបំណងខាងលើ ដោយឈរលើក្របខ័ណ្ឌទស្សនាទាន : ទទួលយក សម្របបច្ចេកវិទ្យានិងនវានុវត្តបន្ថែម គោលដៅត្រូវបានកំណត់ដូចខាងក្រោម៖

៤.១- កសាងនិងពង្រឹងធនធានមនុស្សឱ្យបានគ្រប់គ្រាន់ទាំងបរិមាណ ទាំងគុណភាព និងសមាសភាព មានសីលធម៌វិជ្ជាជីវៈ ដោយពិនិត្យពិចារណាទៅលើកត្តាសមភាពយេនឌ័រ។

៤.២- ផ្តល់លទ្ធភាពឱ្យធនធានមនុស្សឆ្នើមផ្នែក វ.ប.ន. បំពេញភារកិច្ចឈានមុខ និងមានយន្តការសម្រាំង និងលើកទឹកចិត្តសមស្រប ដើម្បីឱ្យបានធនធានមនុស្សផ្នែក វ.ប.ន. ជាតិពេញសមត្ថភាព។

៤.៣- ផ្តល់លទ្ធភាពដល់សកម្មភាពស្រាវជ្រាវនិងអភិវឌ្ឍជាតិប្រកបដោយប្រសិទ្ធភាព និងសក្តិសិទ្ធិភាព ដោយផ្តោតលើការសម្របបច្ចេកវិទ្យាដែលទទួលបានទៅនឹងស្ថានភាពជាក់ស្តែងក្នុងស្រុកជាមួយគ្នានោះ បង្កើនសមត្ថភាពស្រូបយកបច្ចេកវិទ្យាអន្តរជាតិ។

៤.៤- កសាងនិងពង្រឹងប្រព័ន្ធអេកូនវានុវត្តន៍ឱ្យបានប្រកបដោយជវភាព មានសមត្ថភាពសំយោគ បច្ចេកវិទ្យានិងវិស្វកម្មឱ្យបានជាស្នាដៃជាតិមានកម្រិតនវានុវត្តន៍កាន់តែប្រសើរ សំដៅលើកស្ទួយ ឧស្សាហកម្មនិងធុរកិច្ចជាអាទិភាពជាតិ បម្រើឱ្យការប្រើប្រាស់ក្នុងស្រុកនិងការនាំចេញ ដើម្បី ការអភិវឌ្ឍកាន់តែប្រសើរឡើង។

៤.៥- បណ្តុះឱ្យមានវប្បធម៌ វ.ប.ន. នៅក្នុងសង្គម ប្រកបដោយបរិយាបន្ន មានទំនុកចិត្តនិងជំនឿជា សាធារណៈលើផលិតផលនិងសេវាដែលប្រើបច្ចេកវិទ្យាជាតិ ទទួលបាននូវការពេញចិត្តទៅលើ លទ្ធផលនៃការខិតខំនិងការវិនិយោគលើការអភិវឌ្ឍ វ.ប.ន. របស់ខ្លួន ក៏ដូចជា ទៅលើការ កែទម្រង់អភិបាលកិច្ចផ្នែក វ.ប.ន.។

## ៥- យុទ្ធសាស្ត្រ

ដើម្បីសម្រេចបាននូវចក្ខុវិស័យ គោលបំណង និងគោលដៅ ដែលបានកំណត់ខាងលើ និងដើម្បីឱ្យ គោលនយោបាយជាតិ វ.ប.ន. នេះអនុវត្តទៅប្រកបដោយភាពរលូននិងប្រសិទ្ធភាព យុទ្ធសាស្ត្រសំខាន់ៗ មានដូចខាងក្រោម៖

**៥.១- កសាងនិងពង្រឹងធនធានមនុស្សឱ្យបានគ្រប់គ្រាន់ ទាំងបរិមាណ ទាំងគុណភាព និងសមាសភាព មានសីលធម៌វិជ្ជាជីវៈ ដោយពិនិត្យពិចារណាទៅលើកត្តាសមភាពយេនឌ័រ**

៥.១.១- ប្រើប្រាស់ ពង្រឹង និងលើកកម្ពស់ធនធានមនុស្សដែលមានស្រាប់ តាមរយៈការបណ្តុះបណ្តាលនិងបំពេញវិជ្ជាបន្ថែមសម្រាប់តម្រូវការចំពោះមុខ។

៥.១.២- ផ្តល់ឱកាសឱ្យធនធានមនុស្សដែលបាននិងទទួលការកសាងសមត្ថភាពចូលរួមក្នុងកិច្ចការ វ.ប.ន. និងការសហស្រាវជ្រាវក្នុងនិងក្រៅប្រទេសដើម្បីផ្សារភ្ជាប់ការសិក្សានឹងការអនុវត្តជាក់ស្តែង។

៥.១.៣- គាំទ្រការផ្តល់ចំណេះដឹងនិងជំនាញពីក្នុងនិងក្រៅប្រទេស។

៥.១.៤- ទាក់ទាញអ្នកមានទេពកោសល្យចាំបាច់ពីបរទេស ដោយមានការលើកទឹកចិត្តសមស្រប។

៥.១.៥- ធ្វើការសម្រាំងធនធានមនុស្សសម្រាប់ការអប់រំ និងអប់រំបន្ថែមនៅប្រទេសដែលមានការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍន៍ និងការអភិវឌ្ឍ វ.ប.ន. ខ្ពស់ សម្រាប់រយៈពេលមធ្យម និងវែង និងរៀបចំបង្កើតបណ្តាញនិងបណ្តុំបញ្ញវន្ត និងបណ្តាញឧស្សាហកម្មក្នុងនិងក្រៅប្រទេសដោយផ្អែកលើធនធានមនុស្សទាំងនេះ និងដោយមានការគាំទ្រពីកិច្ចការទូត។

**៥.២- ផ្តល់លទ្ធភាពឱ្យធនធានមនុស្សផ្នែក វ.ប.ន. បំពេញភារកិច្ចឈានមុខ និងមានយន្តការសម្រាំង និងលើកទឹកចិត្តសមស្រប ដើម្បីឱ្យបានធនធានមនុស្សផ្នែក វ.ប.ន.ជាតិ ពេញសមត្ថភាព**

៥.២.១- ផ្តល់លទ្ធភាពឱ្យធនធានមនុស្សដែលបានកសាងហើយបំពេញភារកិច្ចអស់សមត្ថភាព។

៥.២.២- តាមដានពិនិត្យ វាយតម្លៃ និងជួយដោះស្រាយបញ្ហានិងកត្តាប្រឈមចំពោះការបំពេញភារកិច្ចរបស់អ្នកវិទ្យាសាស្ត្រ។

៥.២.៣- កសាងនិងដំណើរការឱ្យប្រកបដោយប្រសិទ្ធភាព សុក្រឹតភាព និងនិរន្តរភាព នូវយន្តការវាយតម្លៃ និងប្រព័ន្ធសម្រាំងទេពកោសល្យ ដើម្បីលើកទឹកចិត្តជាធនធាន និងកិត្តិយសដល់ធនធានមនុស្សដែលមានស្នាដៃ និងស្នាដៃឆ្នើម សំដៅលើកកម្ពស់ទេពកោសល្យជាតិ។

៥.២.៤- បង្កើតកម្មវិធី វ.ប.ន. ជាតិដោយឡែកសម្រាប់យុវជននិងយុវនារី ស្ថិតក្នុងដំណាក់កាលពង្រឹងសមត្ថភាពនៅគ្រប់ទីកន្លែង។

**៥.៣- ផ្តល់លទ្ធភាពដល់សកម្មភាពស្រាវជ្រាវនិងអភិវឌ្ឍជាតិប្រកបដោយប្រសិទ្ធភាពនិងសក្តិសិទ្ធិភាព ដោយផ្តោតលើការសម្របបច្ចេកវិទ្យាដែលទទួលបានទៅនឹងស្ថានភាពជាក់ស្តែងក្នុងស្រុកជាមួយគ្នានោះ បង្កើនសមត្ថភាពស្រូបយកបច្ចេកវិទ្យាអន្តរជាតិ**

៥.៣.១- បង្កើននិងគ្រប់គ្រងធនធានសម្រាប់ការស្រាវជ្រាវនិងអភិវឌ្ឍន៍ឱ្យមានប្រសិទ្ធភាពនិងសក្តិសិទ្ធិភាព ដោយឆ្លើយតបនឹងតម្រូវការដោយឡែកនៃ វ.ប.ន. និងគាំទ្រគោលការណ៍បី គឺ (១) ការប្រកួតប្រជែងពីគ្រប់ស្ថាប័ននិងគ្រប់មជ្ឈដ្ឋាននិងការកំណត់គម្រោងជាអាទិភាពជាតិសម្រាប់អ្នកវិទ្យាសាស្ត្រមានទេពកោសល្យឆ្នើម (២) អត្ថិភាពនៃមូលដ្ឋានគ្រឹះ វ.ប.ន. និង (៣) ការជំរុញនវានុវត្តន៍នៃផលិតផល ផលិតភាព និងសេវាកម្ម។

៥.៣.២- ធានាឱ្យមានមូលដ្ឋានបរិក្ខារ សម្ភារៈ និងហេដ្ឋារចនាសម្ព័ន្ធនៃការស្រាវជ្រាវនិងអភិវឌ្ឍន៍ដែលត្រូវការជាក់ស្ដែង។ ដើម្បីប្រសិទ្ធភាព បង្កើតមជ្ឈមណ្ឌលស្រាវជ្រាវវិទ្យាសាស្ត្រជាអាទិភាពជាតិសម្រាប់ប្រើរួមគ្នាតាមជំនាញនីមួយៗដែលប្រតិបត្តិដោយអ្នកបច្ចេកទេសជំនាញ បំពេញឱ្យមូលដ្ឋានវិទ្យាសាស្ត្រដែលមាននៅតាមស្ថាប័នស្រាវជ្រាវវិទ្យាសាស្ត្រ ជាមួយគ្នានេះ កសាងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ស្ថិតិថ្នាក់ជាតិប្រកបដោយបច្ចុប្បន្នភាពស្ដីពីចំនួន លក្ខណៈ និងការប្រើប្រាស់នៃរបស់ទាំងនោះ។

៥.៣.៣- កំណត់សមាមាត្រ១-២-៧ សម្រាប់ការវិនិយោគលើការស្រាវជ្រាវបឋម - ការស្រាវជ្រាវអនុវត្តន៍ - ការអភិវឌ្ឍដោយពិសោធន៍ ដើម្បីផ្ដល់អាទិភាពឱ្យនវានុវត្តន៍។

៥.៣.៤- ផ្ដល់អាទិភាពលើការផ្ទេរនិងការនាំចូលបច្ចេកវិទ្យាដែលជាតម្រូវការចាំបាច់ដើម្បីធ្វើមូលដ្ឋាននីយកម្មសំដៅទទួលបាននវានុវត្តន៍បន្ថែម ដោយផ្អែកលើយុទ្ធសាស្ត្រ "ទិញខ្លះ និងបង្កើតខ្លះ"។

៥.៣.៥- កំណត់ដែនបច្ចេកវិទ្យាប្រកបដោយសក្ដានុពលចំនួនប្រាំជាអាទិភាពជាតិ : (១) ការបង្កើនទិន្នផល ពិពិធកម្ម និងការកែច្នៃផលិតផលកសិកម្ម (២) ផលិតកម្ម និងវិស្វកម្មទំនើប (៣) សុខាភិបាល និងវិទ្យាសាស្ត្រឱសថជីវសាស្ត្រ (៤) វិទ្យាសាស្ត្រ និងវិស្វកម្មវត្ថុធាតុ និង(៥) សេដ្ឋកិច្ចនិងសេវាឌីជីថល។ ជាមួយគ្នានេះ យកចិត្តទុកដាក់តាមដាននិងប្រើប្រាស់បច្ចេកវិទ្យាដែលបានផុសចេញថ្មីៗ ដូចជាបច្ចេកវិទ្យាដែលមានលក្ខណៈរំលោភសិប្បនិម្មិត បច្ចេកវិទ្យាអវកាស និងបច្ចេកវិទ្យាព័ត៌មានលម្អ ដែលមានសមត្ថភាពផ្ដល់ឱ្យនូវការគ្រប់គ្រងកម្រិតម៉ាក្រូប្រកបដោយបច្ចុប្បន្នភាព។

៥.៣.៦- បង្កើតកម្មវិធីជាតិការស្រាវជ្រាវនិងអភិវឌ្ឍន៍ ដើម្បីទាក់ទាញនិងប្រើប្រាស់ធនធានមនុស្ស ធនធានហិរញ្ញវត្ថុ និងកិច្ចសហប្រតិបត្តិការ ក្នុងនិងក្រៅប្រទេស ដើម្បីសម្រេចការអភិវឌ្ឍ វ.ប.ន. ជាអាទិភាពជាតិ។

**៥.៤- កសាងនិងពង្រឹងប្រព័ន្ធអេកូនវានុវត្តន៍ឱ្យបានប្រកបដោយជីវភាព មានសមត្ថភាពសំយោគបច្ចេកវិទ្យានិងវិស្វកម្មឱ្យបានជាស្នាដៃជាតិ មានកម្រិតនវានុវត្តន៍កាន់តែប្រសើរ សំដៅលើកស្ទួយឧស្សាហកម្មនិងធុរកិច្ចជាអាទិភាពជាតិ បម្រើឱ្យការប្រើប្រាស់ក្នុងស្រុកនិងការនាំចេញ ដើម្បីការអភិវឌ្ឍកាន់តែប្រសើរឡើង**

៥.៤.១- បង្កើតកម្មវិធីនវានុវត្តន៍ជាតិដើម្បីគាំទ្រ ជំរុញ សម្របសម្រួល និងភ្ជាប់ទំនាក់ទំនងរវាងគ្រឹះស្ថានសិក្សាជាន់ខ្ពស់ វិទ្យាស្ថានស្រាវជ្រាវ និងសហគ្រាសអាជីវកម្ម ធ្វើឱ្យការស្រាវជ្រាវបានក្លាយទៅជានវានុវត្តន៍ឆាប់រហ័ស មានប្រយោជន៍សម្រាប់សង្គម សេដ្ឋកិច្ច។

៥.៤.២- តម្រូវឱ្យអង្គភាពឬស្ថាប័នស្រាវជ្រាវនិងអភិវឌ្ឍមានផ្នែកផ្ទេរបច្ចេកវិទ្យា មានភារកិច្ចទទួលនិងភ្ជាប់ទំនាក់ទំនងក្នុងប្រព័ន្ធអេកូនវានុវត្តន៍ ភ្ជាប់តម្រូវការបច្ចេកវិទ្យានឹងការអភិវឌ្ឍបច្ចេកវិទ្យា មានកម្មវិធីផ្សព្វផ្សាយ ពន្យល់ និងការគាំទ្រទូលំទូលាយ ក្រោមយន្តការសម្របសម្រួលថ្នាក់ជាតិ។

៥.៤.៣- ចូលរួមបង្កើតនិងគាំទ្រកម្មវិធីបណ្តុះសហគ្រិនភាពរបស់រដ្ឋនិងឯកជន ផ្តល់ឥណទាន និងហិរញ្ញប្បទាន លើកទឹកចិត្ត ជំរុញការបង្កើតដៃគូរវាងឯកជននិងឯកជន និងរវាងឯកជននិងសាធារណៈ ជាតិនិងអន្តរជាតិ ជំរុញនិងបង្កើនការចូលរួមរបស់ឧស្សាហកម្មទំនុកបម្រុងនិងបង្កើនសមត្ថភាពសហគ្រាសតូចនិងមធ្យម ជាមួយគ្នានោះ គាំទ្រសាជីវកម្មខ្នាតធំឱ្យមានសមត្ថភាពនវានុវត្តន៍កាន់តែខ្ពស់។

៥.៤.៤- កសាងនិងលើកទឹកចិត្តឱ្យបង្កើតសួនបច្ចេកវិទ្យានិងសួននវានុវត្តន៍ ដើម្បីជាថ្នាលស្រូបយកបន្ស៊ាំបច្ចេកវិទ្យា សំយោគបច្ចេកវិទ្យានិងវិស្វកម្មដើម្បីនវានុវត្តន៍ អភិវឌ្ឍស្នាដៃព្រាង និងបណ្តុះសហគ្រិនភាពជាតិ។

៥.៤.៥- ជំរុញនិងគាំទ្រកិច្ចការពាណិជ្ជូបនីយកម្មផលិតផល វិធីសាស្ត្រ និងសេវាកម្មនៃបច្ចេកវិទ្យានិងស្នាដៃជាតិ ដើម្បីឱ្យមានការទុកចិត្តនិងការចូលចិត្ត ក្នុងក្របខ័ណ្ឌជាតិនិងអន្តរជាតិ ប្រកបដោយមោទនភាពជាតិ។

៥.៤.៦- រដ្ឋនិងឯកជនខិតខំរួមគ្នាក្នុងការវិនិយោគលើការស្រាវជ្រាវនិងនវានុវត្តន៍ ធ្វើឱ្យសន្ទស្សន៍នវានុវត្តន៍សាកល បានដល់កម្រិតសន្ទស្សន៍នវានុវត្តន៍មធ្យមរបស់អាស៊ាន។

**៥.៥- បណ្តុះឱ្យមានវប្បធម៌ វ.ប.ន. នៅក្នុងសង្គម ប្រកបដោយបរិយាបន្ន មានទំនុកចិត្តនិងជំនឿជាសាធារណៈ លើផលិតផលនិងសេវាបច្ចេកវិទ្យាជាតិ ទទួលបាននូវការពេញចិត្តទៅលើលទ្ធផលនៃការខិតខំនិងការវិនិយោគលើការអភិវឌ្ឍ វ.ប.ន. របស់ខ្លួន ក៏ដូចជាទៅលើការកែទម្រង់អភិបាលកិច្ចផ្នែក វ.ប.ន.**

៥.៥.១- រដ្ឋ ឯកជន និងសង្គម រួមគ្នាពង្រឹងប្រព័ន្ធអប់រំ ការបណ្តុះបណ្តាល និងប្រព័ន្ធផ្សព្វផ្សាយដែលមានគុណសម្បត្តិ "វិទ្យាសាស្ត្រសម្រាប់ទាំងអស់គ្នា" ប្រកបដោយសីលធម៌វិជ្ជាជីវៈ និងមានការលើកទឹកចិត្តឱ្យមានសមត្ថភាពច្នៃប្រឌិត នវានុវត្តន៍ និងសហគ្រិនភាព។

៥.៥.២- បណ្តុះស្មារតីទុកចិត្តលើបច្ចេកវិទ្យាជាតិនិងការចូលចិត្តផលិតផលនិងស្នាដៃជាតិ ដោយការពន្យល់ និងការបង្ហាញពីលក្ខណៈពិសេសឬលក្ខណៈធម្មជាតិរបស់វា។ លទ្ធកម្មសាធារណៈ ត្រូវធ្វើជាគំរូក្នុងកិច្ចការនេះ ដោយធានាថា សម្ភារៈដែលត្រូវធ្វើលទ្ធកម្មត្រូវមានតម្លៃបន្ថែមជាតិឬស្នាដៃជាតិ។ ជាមួយគ្នានេះ គុណភាពនិងតម្លៃនៃសម្ភារៈគួរត្រូវបានកែលម្អជាប្រចាំតាមរយៈប្រព័ន្ធស្រាវជ្រាវនិងនវានុវត្តន៍ជាតិ។

៥.៥.៣- កសាងហេដ្ឋារចនាសម្ព័ន្ធ វ.ប.ន. សាធារណៈ សម្រាប់សហគមន៍ ដូចជា បណ្ណាល័យ សារមន្ទីរ និងបង្កើតវេទិកា ទិវា និងព្រឹត្តិការណ៍ វ.ប.ន. ជំរុញការចូលរួម ការគាំទ្រ និងបង្កើតវប្បធម៌នៃការច្នៃប្រឌិត នវានុវត្តន៍ បង្កើនទំនិញសម្គាល់ភូមិសាស្ត្រ និងសហគ្រិនភាពនៅតាមសហគមន៍។

៥.៥.៤- បង្កើតកាលានុវត្តភាពឱ្យធុរកិច្ចប្រកបដោយបរិយាបន្ន និងសហគ្រាសសង្គម ដែលមានការទទួលខុសត្រូវចំពោះសង្គមនិងបរិស្ថាននៅគ្រប់ទីកន្លែង។

## ៦- ផែនការសកម្មភាព

ដើម្បីសម្រេចបាននូវយុទ្ធសាស្ត្រនៃគោលនយោបាយនេះ ផែនការសកម្មភាពត្រូវបានកំណត់ដូចខាងក្រោម៖

### ៦.១- ការបង្កើតយន្តការ

ដើម្បីគាំទ្រដំណើរការអនុវត្តគោលនយោបាយជាតិនេះ ត្រូវបង្កើតយន្តការដូចខាងក្រោម៖

៦.១.១- ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវមានផ្នែកទទួលបន្ទុក វ.ប.ន. និងមានការស្រាវជ្រាវនិងនវានុវត្តន៍ មានភារកិច្ចចម្បងគឺដើម្បីចូលរួម គាំទ្រ ពង្រឹង និងភ្ជាប់បណ្តាញនវានុវត្តន៍ជាអាទិភាពរបស់វិស័យខ្លួននឹងរបស់ជាតិ។

៦.១.២- ពង្រឹងនិងសម្រួលសេវាសាធារណៈផ្នែក វ.ប.ន. សំខាន់ៗ ដូចជាកិច្ចការដែលពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញា ស្តង់ដាជាតិសម្រាប់វិញ្ញាបនកម្ម និងការទទួលស្គាល់សម្បទាបច្ចេកវិទ្យា ដើម្បីបង្កើនការជឿជាក់លើស្នាដៃជាតិ ប្រកបដោយមោទនភាពជាតិ និងការទុកចិត្តជាសាកល ដោយជំរុញការប្រើប្រាស់ស្នាដៃដែលមានស្រាប់។

៦.១.៣- ពង្រឹងតួនាទី ភារកិច្ច និងកិច្ចសហការរបស់ស្ថាប័ន វ.ប.ន. ថ្នាក់ជាតិ ថ្នាក់ក្រសួង ស្ថាប័ន និងថ្នាក់ក្រោមជាតិ និងលើកកម្ពស់សមត្ថកិច្ចនៃស្ថាប័នទាំងនេះក្នុងការកំណត់និងការអនុវត្តរបៀបវារៈវ.ប.ន. និងទំនាក់ទំនងអន្តរជាតិ។

៦.១.៤- សម្រាប់ដែនបច្ចេកវិទ្យានិងប្រព័ន្ធនវានុវត្តន៍ជាអាទិភាពជាតិ ធ្វើការពង្រឹង ក្នុងករណីចាំបាច់ សិក្សានិងកសាងវិទ្យាស្ថានស្រាវជ្រាវដើម្បីមូលដ្ឋាននីយកម្មបច្ចេកវិទ្យាជាអាទិភាពជាតិ សំដៅអភិវឌ្ឍផលិតផលនិងស្នាដៃគំរូ និងទីភ្នាក់ងារ វ.ប.ន. ជំនាញទទួលបន្ទុកបេសកកម្ម វ.ប.ន. ពិសេស ដែលផ្តោតលើកិច្ចការនវានុវត្តន៍។

៦.១.៥- សិក្សាពីលទ្ធភាពបង្កលក្ខណៈឱ្យមានការចូលរួមពីអំណាចនីតិប្បញ្ញត្តិ សម្រាប់ដំណើរការនៃការអនុវត្ត វ.ប.ន. នៅកម្ពុជា។

៦.១.៦- ពង្រឹងការទូតផ្នែកវិទ្យាសាស្ត្រ និងមានរបៀបវារៈ វ.ប.ន. សម្រាប់កិច្ចប្រជុំកម្រិតកំពូល ដើម្បីឱ្យទំនាក់ទំនង វ.ប.ន. ឆ្លងប្រទេសបានប្រព្រឹត្តទៅដោយរលូន។

៦.១.៧- ចូលរួមជាមួយស្ថាប័ន វ.ប.ន. អន្តរជាតិ និងរួមគ្នាជួយជ្រោមជ្រែងការបង្កើតនិងពង្រឹងបណ្តាញធនធានហិរញ្ញវត្ថុ បណ្តាញកសាងធនធានមនុស្ស បណ្តាញការស្រាវជ្រាវនិងនវានុវត្តន៍ បណ្តាញឧស្សាហកម្ម និងបណ្តាញទីផ្សារអន្តរជាតិ។

### ៦.២- ការបង្កើតក្របខ័ណ្ឌគតិយុត្ត

ដើម្បីគាំទ្រដំណើរការអនុវត្តគោលនយោបាយជាតិនេះ ក្របខ័ណ្ឌគតិយុត្តមួយចំនួននឹងត្រូវរៀបចំ៖

៦.២.១- ច្បាប់ពាក់ព័ន្ធនឹងក្របខ័ណ្ឌជាមូលដ្ឋានសម្រាប់ការអភិវឌ្ឍ វ.ប.ន.។

៦.២.២- លិខិតបទដ្ឋានគតិយុត្តចាំបាច់ផ្សេងទៀតដើម្បីពង្រឹងអភិបាលកិច្ច ជំរុញ និងលើកទឹកចិត្តដល់កិច្ចការអភិវឌ្ឍ វ.ប.ន.។

### ៦.៣- ការគាំទ្រហិរញ្ញវត្ថុ

ដើម្បីគាំទ្រយន្តការនិងដំណើរការសកម្មភាពតាមយុទ្ធសាស្ត្រនីមួយៗ គោលនយោបាយនេះត្រូវមានការគាំទ្រហិរញ្ញវត្ថុដែលបានមកពីប្រភពដូចខាងក្រោម៖

៦.៣.១- ថវិកាជាតិដែលជាកញ្ចប់ថវិការបស់ក្រសួងឬស្ថាប័នពាក់ព័ន្ធ។

៦.៣.២- ហិរញ្ញប្បទាននិងអំណោយពីដៃគូអភិវឌ្ឍ វិភាគទានពីវិស័យឯកជន សហគមន៍ សប្បុរសជន ព្រមទាំងថវិកាមកពីប្រភពផ្សេងៗទៀត។

### ៦.៤- ការអភិវឌ្ឍធនធានមនុស្ស

ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយជាតិនេះ ត្រូវយកចិត្តទុកដាក់កសាងនិងពង្រឹងធនធានមនុស្សឱ្យបានគ្រប់គ្រាន់ ទាំងបរិមាណ ទាំងគុណភាព និងសមាសភាពដូចខាងក្រោម៖

៦.៤.១- កសាងនិងរៀបចំឱ្យមានសមាសភាពនៃពីរ៉ាមីតធនធានមនុស្ស វ.ប.ន. ដែលមាន (១) ទីប្រឹក្សា វ.ប.ន. អមនាយករដ្ឋមន្ត្រី (២) អ្នកនាំពាក្យ វ.ប.ន. (៣) អ្នករៀបចំផែនការ និងអ្នកគ្រប់គ្រង វ.ប.ន. (៤) គ្រូបង្វឹក វ.ប.ន. និង(៥) អ្នកប្រតិបត្តិ វ.ប.ន.។

៦.៤.២- អប់រំនិងបណ្តុះបណ្តាលឱ្យមានចំនួនអ្នកស្រាវជ្រាវ និងចំនួនអ្នកបច្ចេកទេសគ្រប់គ្រាន់សម្រាប់កិច្ចការ វ.ប.ន. ស្របតាមតម្រូវការនៃដំណាក់កាលអភិវឌ្ឍន៍នីមួយៗ។

៦.៤.៣- ឥស្សរជនដែលមានចំណេះដឹងនិងបទពិសោធផ្នែក វ.ប.ន.។

៦.៤.៤- អ្នកវិទ្យាសាស្ត្រ សាស្ត្រាចារ្យ និងអ្នកជំនាញ ក្នុងនិងក្រៅប្រទេស ផ្នែក វ.ប.ន.។

៦.៤.៥- មន្ត្រីក្របខ័ណ្ឌនិងឬមន្ត្រីជាប់កិច្ចសន្យាមានសមត្ថភាពនិងទេពកោសល្យផ្នែក វ.ប.ន.។

៦.៤.៦- ការអប់រំនិងបណ្តុះបណ្តាលដើម្បីលើកកម្ពស់សមត្ថភាព ជំនាញ និងសីលធម៌វិជ្ជាជីវៈផ្នែក វ.ប.ន.។

### ៦.៥- ដំណើរការអនុវត្ត

អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា មានភារកិច្ចសម្របសម្រួល និងក្រសួង ស្ថាប័នពាក់ព័ន្ធមានភារកិច្ចសហការរៀបចំផែនការសកម្មភាពលម្អិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនមានប្រភពធនធាន មានពេលវេលា(សម្រាប់រយៈពេលខ្លី មធ្យម និងវែង) និងដោយឈរលើមូលដ្ឋាននៃការប្តេជ្ញាចិត្តអនុវត្តយ៉ាងម៉ឺងម៉ាត់។

## ៧- ការតាមដាន ត្រួតពិនិត្យ និងការវាយតម្លៃ

ដើម្បីលើកកម្ពស់ប្រសិទ្ធភាពក្នុងការអនុវត្តគោលនយោបាយជាតិនេះ ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធត្រូវ៖

៧.១- ចូលរួមបង្កើតនិងអនុវត្តយន្តការនិងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់តាមដានត្រួតពិនិត្យលើការអនុវត្តដោយផ្ទាល់ កែតម្រូវនិងវាយតម្លៃលើការអនុវត្តគោលនយោបាយនេះ វិភាគលើលទ្ធផលនៃការងារប្រតិបត្តិ បូកសរុបលទ្ធផលការងារដែលសម្រេចបាន បញ្ហាប្រឈមនិងផលប៉ះពាល់នានា ព្រមទាំងលើកដៅទិសដៅអនុវត្តបន្ត។

៧.២- ត្រូវយកលទ្ធផលនៃការវាយតម្លៃជាមូលដ្ឋានសម្រាប់ការកែលម្អការងារប្រតិបត្តិដែលនៅខ្វះខាត មិនចំទិសដៅ និងរកដំណោះស្រាយនៃបញ្ហាប្រឈមនានាដើម្បីរៀបចំផែនការការងារថ្មីឱ្យបានសមស្រប។

៧.៣- វាយតម្លៃប្រសិទ្ធភាពការងារនិងតម្រង់ទិសក្នុងក្របខ័ណ្ឌនៃស្ថាប័នកណ្តាល មិនពាក់ព័ន្ធនឹងការអនុវត្តដោយផ្ទាល់ ដែលបច្ចុប្បន្នមានក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា និងក្រសួងស្ថាប័នដែលពាក់ព័ន្ធនៃរចនាសម្ព័ន្ធគ្រប់គ្រង។

## ៨- សេចក្តីសន្និដ្ឋាន

គោលនយោបាយជាតិ វ.ប.ន. នេះ ត្រូវបានរៀបចំឡើងដើម្បីគាំទ្ររបៀបវារៈអភិវឌ្ឍន៍ជាតិ សំដៅឈានដល់ការសម្រេចបាននូវចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ តាមរយៈការពង្រឹងមូលដ្ឋាននិងកសាងសមត្ថភាព វ.ប.ន.ជាតិ ដើម្បីបង្កើតបាននូវបច្ចេកវិទ្យាប្រកបដោយសក្តានុពលសម្រាប់ការអភិវឌ្ឍ បង្កើនសមត្ថភាពនវានុវត្តន៍ សំដៅឆ្លើយតបបានទៅនឹងសេចក្តីត្រូវការជាមូលដ្ឋានរបស់ជាតិ លើកស្ទួយគុណភាពជីវិតរបស់ប្រជាជន បង្កើនធនធានជាតិ កសាងខឿនឧស្សាហកម្មប្រកបដោយសមត្ថភាពប្រកួតប្រជែង ក៏ដូចជាពង្រឹងអភិបាលកិច្ចកាន់តែប្រសើរ។ ក្នុងន័យនេះ គោលនយោបាយជាតិ វ.ប.ន. គឺជាឧបករណ៍ និងជាកម្លាំងជំរុញការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចទៅដំណាក់កាលថ្មី និងប្រកបដោយចីរភាព ដើម្បីសម្រេចបាននូវរបៀបវារៈអភិវឌ្ឍន៍ជាតិ ហើយគោលនយោបាយជាតិនេះមិនផ្តោតជាសំខាន់លើការបង្កើតបាននូវស្នាដៃល្អ និងភាពល្បីល្បាញផ្នែកវិទ្យាសាស្ត្រនោះទេ។

ទន្ទឹមនឹងនេះ ការអភិវឌ្ឍ វ.ប.ន. ប្រកបដោយជោគជ័យទាមទារឱ្យមានការខិតខំរួមគ្នា បង្កើតឡើងនូវបរិស្ថានអនុគ្រោះមួយដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ទាំងកម្រិតនយោបាយ ទាំងកម្រិតបច្ចេកទេសដូចបានលើកឡើងក្នុងគោលនយោបាយជាតិនេះ។ ក្នុងស្មារតីនេះ ការអភិវឌ្ឍ វ.ប.ន. ត្រូវចាត់ទុកជាការងារអាទិភាពអន្តរវិស័យ សម្រាប់យុទ្ធសាស្ត្រជាតិ គោលនយោបាយជាតិ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនានានៅពេលខាងមុខ។

ជារួម ប្រការសំខាន់បំផុតដែលយើងត្រូវផ្តោតការយកចិត្តទុកដាក់លើនោះគឺ ការប្រែក្លាយគោលនយោបាយជាតិនេះឱ្យក្លាយទៅជាសកម្មភាពអនុវត្តជាក់ស្តែង សំដៅសម្រេចឱ្យបានជោគជ័យនូវរបៀបវារៈអភិវឌ្ឍន៍ជាតិ និងប្រកបដោយមោទនភាពជាតិ។

## សទ្ទានុក្រម[១]

**ការស្រាវជ្រាវនិងអភិវឌ្ឍន៍**(scientific research and experimental development or research and development or R&D) សំដៅដល់សកម្មភាពស្នូលនៃវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា។ ការងារប្រកបដោយការច្នៃប្រឌិតនិងមានលក្ខណៈជាប្រព័ន្ធផ្អែកលើចំណេះដឹងដែលមាន ដើម្បីបង្កើតថ្មី ធ្វើឱ្យប្រសើរឡើង និងបង្កើននូវសន្និធិនៃចំណេះដឹង សម្រាប់មនុស្សជាតិ។ ការស្រាវជ្រាវនិងអភិវឌ្ឍន៍មានបីប្រភេទ ឬដំណាក់កាល : ១/ការស្រាវជ្រាវបឋម (basic research) ២/ការស្រាវជ្រាវអនុវត្តន៍ (applied research) និង៣/ការអភិវឌ្ឍដោយពិសោធន៍(experimental development)។

សកម្មភាពដែលមិនត្រូវបានចាត់ទុកជាការស្រាវជ្រាវនិងអភិវឌ្ឍន៍ រួមមានការផ្តល់ប្រឹក្សា ការអប់រំនិងការបណ្តុះបណ្តាល។ ដោយឡែក ការស្រាវជ្រាវដោយនិស្សិតថ្នាក់បណ្ឌិតនៅសាកលវិទ្យាល័យត្រូវបានចាត់ទុកជាការស្រាវជ្រាវនិងអភិវឌ្ឍន៍ តាមការគួរ ការប្រមូលទិន្នន័យជាប្រចាំ សម្រាប់គោលបំណងទូទៅ ការសិក្សាទីផ្សារ ការសាកល្បង ឬការពិសោធជាប្រចាំ ការសិក្សាពីលទ្ធភាពដូចជាការសិក្សាស្រាវជ្រាវពីគម្រោងវិស្វកម្ម ដោយប្រើប្រាស់បច្ចេកទេសដែលមានស្រាប់(លើកលែងតែវាជាចំណែកនៃការស្រាវជ្រាវនិងការអភិវឌ្ឍន៍) ការសិក្សាស្រាវជ្រាវជាប្រចាំនៃវេជ្ជសាស្ត្រជំនាញ ឧទាហរណ៍ ការធ្វើរោគវិនិច្ឆ័យជាអាទិ៍ កិច្ចការរដ្ឋបាលនិងកិច្ចការច្បាប់ពាក់ព័ន្ធ នឹងការផ្តល់ប្រកាសនីយបត្រតក្កកម្ម(patent) និងអាជ្ញាបណ្ណ។ ដោយឡែក កិច្ចការដែលទាក់ទងផ្ទាល់នឹងការទទួលប្រកាសនីយបត្រតក្កកម្មនៃការស្រាវជ្រាវនិងអភិវឌ្ឍន៍ ត្រូវបានរាប់បញ្ចូលជាការស្រាវជ្រាវនិងអភិវឌ្ឍន៍ សកម្មភាពដែលពាក់ព័ន្ធនឹងកម្មវិធីកុំព្យូទ័រ ដែលមានលក្ខណៈជាប្រចាំ។

**ការស្រាវជ្រាវបឋម**(basic research pure research or fundamental research) សំដៅដល់ការស្រាវជ្រាវនិងការពិសោធវិទ្យាសាស្ត្រសំដៅរៀបចំទ្រឹស្តី និងក្បួនខ្នាតដែលត្រូវបានអនុវត្តជាចម្បងដើម្បីពន្យល់ ឬព្យាករណ៍បាតុភូតធម្មជាតិ និងទិដ្ឋភាពសច្ចភាព ដោយមិនបានគិតអំពីការប្រើប្រាស់ចំណេះដឹងនេះជាក់ស្តែងទេ។

**ការស្រាវជ្រាវអនុវត្តន៍**(applied research) សំដៅដល់ការស្រាវជ្រាវនិងការពិសោធដោយប្រើប្រាស់ទ្រឹស្តីវិទ្យាសាស្ត្រ មានគោលបំណងជាចម្បងគឺដើម្បីទទួលបានបច្ចេកវិទ្យា ឬបច្ចេកទេសសម្រាប់អន្តរាគមន៍ ធម្មជាតិ ឬបាតុភូតនានា សំដៅការប្រើប្រាស់ជាក់ស្តែងណាមួយ។

**ការអភិវឌ្ឍដោយពិសោធន៍**(experimental development) សំដៅដល់ការស្រាវជ្រាវនិងការពិសោធមានលក្ខណៈជាប្រព័ន្ធ សំដៅបង្កើតផលិតផលថ្មី វិធីសាស្ត្រថ្មី ឬសេវាថ្មី ឬកាន់តែប្រសើរឡើង ដោយប្រើប្រាស់ចំណេះដឹងដែលទទួលបានពីការស្រាវជ្រាវនិងបទពិសោធវិទ្យាសាស្ត្រ។

---

[១] វាក្យសព្ទទាំងនេះបានផ្អែកជាចម្បងលើឯកសាររបស់ អង្គការសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងការអភិវឌ្ឍ (Organization for Economic Cooperation and Development ឬ OECD)។

**ចំណាយក្នុងស្រុកសរុបលើការស្រាវជ្រាវនិងអភិវឌ្ឍន៍**(Gross Domestic Expenditure on R&D or GERD) សំដៅដល់ការចំណាយក្នុងស្រុកសរុប(ជាសាច់ប្រាក់និងការទូទាត់បញ្ជី)លើការស្រាវជ្រាវនិងអភិវឌ្ឍន៍ ជាទូទៅត្រូវបានបង្ហាញជាភាគរយនៃផលិតផលក្នុងស្រុកសរុប(GDP)។ ការគណនាមានរួមបញ្ចូល ការចំណាយចរន្តនិងការចំណាយមូលធន ប៉ុន្តែតម្លៃនៃការរំលស់មិនត្រូវបានរាប់បញ្ចូលទេ។

**បច្ចេកវិទ្យា**(Technology) សំដៅដល់ការប្រើប្រាស់ចំណេះដឹងអំពីធម្មជាតិ សម្រាប់ជាប្រយោជន៍របស់មនុស្សជាតិ។

**បរិយាបន្ន**(Inclusive) សំដៅដល់ការលើកកម្ពស់លទ្ធភាពរបស់បុគ្គលនិងក្រុមនានាក្នុងការចូលរួម និងទទួលផលពីសកម្មភាពនានារបស់សង្គមដោយមិនរើសអើង។ គោលបំណងនៃបរិយាបន្ន គឺការផ្តល់នូវសិទ្ធិដល់ក្រុមផ្សេងៗ ជាពិសេសប្រជាពលរដ្ឋក្រីក្រ ក្រុមជនងាយរងគ្រោះឱ្យទទួលបាននូវឱកាសសមស្រប ព្រមទាំងធានាថាមតិយោបល់ និងការយល់ឃើញនានារបស់ក្រុមទាំងនោះត្រូវបានយកមកពិចារណាសម្រាប់ការធ្វើសេចក្តីសម្រេចចិត្ត ដែលប៉ះពាល់ដល់ជីវភាពរស់នៅរបស់ពួកគេ ក៏ដូចជាដើម្បីធានាឱ្យពួកគេទទួល និងប្រើប្រាស់ដោយស្មើភាពនូវផលប្រយោជន៍ពីការផ្តល់សេវា ការអភិវឌ្ឍមូលដ្ឋាន និងលក្ខខណ្ឌនានាផ្នែកសង្គម នយោបាយ និងរូបវន្ត។ [ដកស្រង់ចេញពីសៀវភៅផែនការអនុវត្តរយៈពេលបីឆ្នាំដំណាក់កាលទីពីរ(២០១៥-២០១៧) នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ]។

**បុគ្គលិកគាំទ្រ**(supporting staff) សំដៅដល់សិប្បករជំនាញនិងមិនជំនាញ លេខាធិការ និងស្មៀន ដែលចូលរួមដោយផ្ទាល់ ឬផ្តល់សេវាកម្មដល់អ្នកស្រាវជ្រាវក្នុងគម្រោងស្រាវជ្រាវនិងអភិវឌ្ឍ។ ត្រូវបានរាប់បញ្ចូលផងដែរនូវអ្នកគ្រប់គ្រង និងនាយកទាំងឡាយណាដែលជាប់ពាក់ព័ន្ធជាសំខាន់ជាមួយនឹងការងារថវិកា និងធនធានមនុស្សក្នុងការគាំទ្រដល់កិច្ចការស្រាវជ្រាវជាងការគ្រប់គ្រងបច្ចេកទេសនៃគម្រោងស្រាវជ្រាវដោយផ្ទាល់។

**នវានុវត្តន៍**(innovation) សំដៅដល់ការអនុវត្តពុទ្ធិដើម្បីទទួលបានផលិតផល(ទំនិញឬសេវា) ឬវិធីសាស្ត្រដែលថ្មី ឬប្រសើរជាង គួរឱ្យកត់សម្គាល់។

**វិទ្យាសាស្ត្រ**(science) សំដៅដល់ចំណេះដឹងអំពីធម្មជាតិ។

**សមមូលនៃរយៈពេលពេញម៉ោង**(full-time equivalent or FTE) សំដៅដល់ឯកតារង្វាស់នៃបុគ្គលិក/កម្លាំងពលកម្ម ផ្នែកការស្រាវជ្រាវនិងអភិវឌ្ឍន៍។ សមមូលនៃរយៈពេលពេញម៉ោង(FTE)មួយ អាចត្រូវបានចាត់ទុកថាជាកម្លាំងពលកម្មមួយឆ្នាំពេញនៃមនុស្សម្នាក់។ ដូចនេះ មនុស្សម្នាក់ដែលជាធម្មតាចំណាយ ៣០%នៃពេលវេលារបស់គាត់ទៅលើការស្រាវជ្រាវនិងអភិវឌ្ឍន៍ និងប្រើពេលដែលនៅសល់សម្រាប់សកម្មភាពផ្សេងទៀត(ដូចជាការបង្រៀន កិច្ចការរដ្ឋបាលរបស់សាកលវិទ្យាល័យ និងការផ្តល់ប្រឹក្សាដល់សិស្ស) ត្រូវបានចាត់ទុកថាស្មើ០,៣ សមមូលនៃរយៈពេលពេញម៉ោង(FTE)ក្នុងកិច្ចការស្រាវជ្រាវ។

ដូចគ្នានេះដែរ ប្រសិនបើមានពលករធ្វើការពេញម៉ោងក្នុងផ្នែកការស្រាវជ្រាវនិងអភិវឌ្ឍន៍ និងត្រូវបានគេជួលឱ្យធ្វើការសម្រាប់តែរយៈពេលប្រាំមួយខែ នោះការងារសមមូលនៃរយៈពេលពេញម៉ោងនៃការងាររបស់គាត់គឺ០,៥។ អាស្រ័យដោយថ្ងៃធ្វើការ(រយៈពេលធ្វើការ) ជាធម្មតា អាចខុសគ្នាពីវិស័យមួយទៅវិស័យមួយទៀត និងពីស្ថាប័នមួយទៅស្ថាប័នមួយទៀត វាជាការមិនត្រឹមត្រូវក្នុងការបង្ហាញសមមូលនៃរយៈពេលពេញម៉ោង(FTE)គិតជាម៉ោងនៃពលកម្មទេ។

**សហគ្រាសសង្គម**(Social Enterprise) សំដៅដល់អង្គភាពដែលអនុវត្តយុទ្ធសាស្ត្រធុរកិច្ចដើម្បីទទួលបានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុ ជាមួយគ្នានឹងផលប្រយោជន៍សង្គម បរិយាកាសជាអតិបរមា។

**អ្នកបច្ចេកទេស**(technician) សំដៅដល់អ្នកដែលធ្វើការងារបច្ចេកទេសដើម្បីគាំទ្រដល់ការស្រាវជ្រាវនិងអភិវឌ្ឍន៍ ហើយជាធម្មតាស្ថិតនៅក្រោមការដឹកនាំ និងការត្រួតពិនិត្យផ្ទាល់របស់អ្នកស្រាវជ្រាវ។

**អ្នកស្រាវជ្រាវ**(researcher) សំដៅដល់ជាអ្នកជំនាញអាជីព ដែលផ្តល់ទស្សនទាន ឬបង្កើតចំណេះដឹងថ្មី ផលិតផលថ្មី យន្តការថ្មី វិធីសាស្ត្រថ្មី និងប្រព័ន្ធថ្មី និងអ្នកដែលចូលរួមចាត់ចែងគម្រោងនៃការស្រាវជ្រាវនិងអភិវឌ្ឍន៍ដែលពាក់ព័ន្ធ។ ពួកគាត់ជាអ្នកវិទ្យាសាស្ត្រ វិស្វករ និងគ្រូបង្រៀន ត្រូវបានរាប់បញ្ចូលជាអ្នកស្រាវជ្រាវផងដែរ ចំពោះអ្នកគ្រប់គ្រង និងអភិបាលរដ្ឋបាល ដែលចូលរួមការរៀបចំផែនការ និងការគ្រប់គ្រងផ្នែកវិទ្យាសាស្ត្រនិងបច្ចេកទេសនៃការងាររបស់អ្នកស្រាវជ្រាវ។ ជាធម្មតាឋានៈរបស់គាត់ស្មើឬខ្ពស់ជាងអ្នកស្រាវជ្រាវ ហើយជារឿយៗ គាត់គឺជាអតីតអ្នកស្រាវជ្រាវឬបច្ចុប្បន្នជាអ្នកស្រាវជ្រាវក្រៅម៉ោង។ មិនត្រូវបានរាប់បញ្ចូលជាអ្នកស្រាវជ្រាវទេចំពោះអ្នកគ្រប់គ្រង និងនាយកទាំងឡាយណាដែលជាប់ពាក់ព័ន្ធជាសំខាន់ជាមួយនឹងការងារថវិកា និងធនធានមនុស្សជាងការគ្រប់គ្រង ឬការងារស្នូលរបស់គម្រោងការស្រាវជ្រាវនិងអភិវឌ្ឍន៍(រាប់បញ្ចូលនៅក្នុងផ្នែក "បុគ្គលិកដទៃទៀតដែលគាំទ្រដោយផ្ទាល់ដល់R&D")។ នៅក្នុងវិស័យអប់រំជាន់ខ្ពស់ អ្នកស្រាវជ្រាវមានដូចខាងក្រោម៖

ក) បុគ្គលិកសិក្សាដែលចូលរួមនិងចាត់ចែងការស្រាវជ្រាវ។

ខ) និស្សិតកម្រិតអនុបណ្ឌិតឬបណ្ឌិតជាជំនួយការការងារស្រាវជ្រាវ។

គ) និស្សិតកំពុងសិក្សាកម្រិតក្រោយបណ្ឌិតទាំងអស់ ដែលស្ថាប័នបានប្រគល់ភារកិច្ចស្រាវជ្រាវជូន។

**សេដ្ឋកិច្ចពុទ្ធិ**(Knowlendge Economy) សំដៅដល់សេដ្ឋកិច្ចដែលអាស្រ័យលើបរិមាណ គុណភាព និងការប្រើប្រាស់ចំណេះដឹងជំនាញ និងព័ត៌មាន ដើម្បីការអភិវឌ្ឍ ជាជាងការអាស្រ័យលើកត្តាផលិតកម្ម ដូចជាកម្លាំងពលកម្ម និងធនធានធម្មជាតិ។

**បច្ចេកវិទ្យាដែលមានលក្ខណៈវៃឆ្លាតសិប្បនិម្មិត**(Artificial Intelligence Technology ឬ AI) សំដៅដល់បច្ចេកវិទ្យាដែលមានបំណងធ្វើឱ្យឧបករណ៍ឬគ្រឿងយន្តមានលក្ខណៈវៃឆ្លាតដូចមនុស្ស។

**បច្ចេកវិទ្យាអវកាស**(Space Technology) សំដៅដល់បច្ចេកវិទ្យាដែលអភិវឌ្ឍពីវិទ្យាសាស្ត្រអវកាស ប្រើសម្រាប់ផ្កាយរណប ការហោះហើរក្នុងអវកាស ឬការរុករកក្នុងអវកាស។

**បច្ចេកវិទ្យាព័ត៌មានលម្ហ**(Spatial Information Technology) សំដៅដល់បច្ចេកវិទ្យាដែលកំណត់និងប្រើប្រាស់ព័ត៌មាននៃទីតាំងក្នុងលម្ហអាកាស លើដី និងក្រោមដី។

**មូលដ្ឋានីយកម្ម**(Localization) សំដៅដល់ការសម្របទៅនឹងស្ថានភាព ឬតម្រូវការក្នុងស្រុក។

**ប្រព័ន្ធអេកូនវានុវត្តន៍**(Innovation Ecosystem) សំដៅដល់ប្រព័ន្ធនៃសមាសភាព(មនុស្ស ស្ថាប័ន កម្មវិធី នីតិវិធី អន្តរាគមន៍ ទីផ្សារ។ល។) និងធនធានសម្រាប់នវានុវត្តន៍។

**ពីរ៉ាមីតធនធានមនុស្ស វ.ប.ន.** (STI Human Capital Pyramid) សំដៅដល់ពីរ៉ាមីតឬសាជីនៃសមាសភាពធនធានមនុស្សរបស់ប្រទេសដែលមានជំនាញនិងកម្រិតផ្សេងគ្នា និងត្រូវការឱ្យសហការគ្នាដើម្បីជោគជ័យនៃការអភិវឌ្ឍវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (វ.ប.ន.)។

**នវានុវត្តន៍ចំហ**(Open Innovation) សំដៅដល់ការប្រើប្រាស់ពុទ្ធិខាងក្នុងនិងពីខាងក្រៅសហគ្រាសឬស្ថាប័នដើម្បីជំរុញនវានុវត្តន៍ និងការពង្រីកទីផ្សារដើម្បីបង្កើនការប្រើប្រាស់នវានុវត្តន៍ទៅខាងក្រៅសហគ្រាសឬស្ថាប័ន។

# បញ្ជីពាក្យកាត់

| ពាក្យកាត់ ខ្មែរ អង់គ្លេស | ពាក្យពេញ ជាភាសាខ្មែរ | ពាក្យពេញ ជាភាសាអង់គ្លេស |
|---|---|---|
| ក.ប. (IP) | កម្មសិទ្ធិបញ្ញា | Intellectual Property |
| គ.ស.ខ. (IHL) | គ្រឹះស្ថានសិក្សាជាន់ខ្ពស់ | Institution of Higher Learning |
| ធ.ប. (IB) | ធុរកិច្ចប្រកបដោយបរិយាបន្ន | Inclusive Business |
| ផ.ស.ស. (GDP) | ផលិតផលក្នុងស្រុកសរុប | Gross Domestic Product |
| ស.អ.ស.រ. (GRI) | ស្ថាប័នអាជីវកម្មនិងស្រាវជ្រាវរដ្ឋ | Government and Research Institute |
| វ.ប.ន. (STI) | វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍ | Science, Technology, and Innovation |
| វ.ប.វ.គ. (STEM) | វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និង គណិតវិទ្យា | Science, Technology, Engineering and Mathematics |
| វ.ប.វ.ស.គ. (STEAM) | វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈ និងគណិតវិទ្យា | Science, Technology, Engineering, Art and Mathematics |
| វ.ស.អ. (GERD) | ការវិនិយោគសរុបលើការស្រាវជ្រាវនិងអភិវឌ្ឍន៍សរុប (រដ្ឋ និង ឯកជន) | Gross Expenditure on Research and Development |
| ស.ន. (R&I) | ការស្រាវជ្រាវនិងនវានុវត្តន៍ | Research and Innovation |
| ស.ន.វ. (GII) | សន្ទស្សន៍នវានុវត្តន៍សាកល | Global Innovation Index |
| ស.ស. (SE) | សហគ្រាសសង្គម | Social Enterprise |
| ស.ស.ម. (NRFTE) | ចំនួនអ្នកស្រាវជ្រាវ គិតជា សមមូលនៃរយៈពេលធ្វើការពេញម៉ោង | Number of Researchers in Full Time Equivalent |
| ស.អ. (R&D) | ការស្រាវជ្រាវនិងអភិវឌ្ឍន៍ | Research and Development |
| ស.អា. (BE) | សហគ្រាសអាជីវកម្ម | Business Enterprise |
| អ.ក.ស.ប.ព. (WIPO) | អង្គការកម្មសិទ្ធិបញ្ញាពិភពលោក | World Intellectual Property Organization |
| អ.ម.រ. (NGO) | អង្គការមិនមែនរដ្ឋាភិបាល | Non-Governmental Organization |

អគ្គលេខាធិការដ្ឋាននៃ ក្រុមប្រឹក្សាជាតិ វិទ្យាសាស្ត្រនិងបច្ចេកវិទ្យា (ក្រសួងផែនការ)៖  ផ្លូវ៣៦០ សង្កាត់បឹងកេងកង១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ
ទូរសព្ទ/ទូរសារ៖ 023 727 035 អ៊ីម៉ែល៖ gs-nstc@snt.gov.kh គេហទំព័រ៖ snt.gov.kh